# សុខភាពបន្តពូជ & ថ្នាំបង្ការជំងឺ COVID-19

ខែកញ្ញា ឆ្នាំ 2021

## ការមានផ្ទៃពោះ

អ្នកមានផ្ទៃពោះ និងអ្នកទើបនឹងមានផ្ទៃពោះថ្មីៗ ដែលឆ្លងជំងឺ COVID-19 គឺទំនងខ្លាំងជាអាចធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ បើប្រៀបធៀបទៅនឹងអ្នកមិនមានផ្ទៃពោះ។[3,4]

អ្នកមានផ្ទៃពោះដែលមានជំងឺ COVID-19 ក៏ទំនងខ្លាំងជាអាចមានបញ្ហាមួយចំនួនទាក់ទងនឹងការមានផ្ទៃពោះនេះដែរដូចជាការសម្រាលមុនពេលកំណត់។[3,4]

មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) មហាវិទ្យាល័យគ្រូពេទ្យឯកទេសផ្នែកសម្ភពនិងរោគស្ត្រីអាមេរិក និងសង្គមវេជ្ជសាស្ត្រសម្រាប់មាតានិងទារក បានផ្តល់ការណែនាំឱ្យអ្នកមានផ្ទៃពោះទាំងអស់ទទួលការចាក់ថ្នាំបង្ការជំងឺ COVID-19។[1]



## ការផលិតទឹកដោះ

មិនមានភស្តុតាងណាមួយដែលបញ្ជាក់ថាជំងឺ COVID-19 ឆ្លងរាលដាលដល់ទារកតាមរយៈការបំបៅទឹកដោះម្តាយនោះទេ។[4]



អ្នកកំពុងបំបៅដោះកូនដែលបានចាក់ថ្នាំបង្ការប្រភេទ Pfizer ឬ Moderna មានអង់ទីក័រ (antibodies) នៅក្នុងទឹកដោះរបស់ពួកគេដែលអាចជួយការពារទារករបស់ពួកគេបាន។[4] ចំណុចនេះមិនទាន់ត្រូវបានរកឃើញចំពោះថ្នាំបង្ការ J&J នៅឡើយទេ។

## ការមករដូវ

មនុស្សមួយចំនួនបានរាយការណ៍ពីការផ្លាស់ប្តូរវដ្តរដូវរបស់ពួកគេបន្ទាប់ពីការចាក់ថ្នាំបង្ការជំងឺ COVID-19 មានទាំងការធ្លាក់ឈាមច្រើនជាមុនឬតិចជាងមុន ឬការហូរឈាមដែលមិនថេរតាមកាលកំណត់។ ការផ្លាស់ប្តូរទាំងនេះគឺជាបណ្តោះអាសន្ន និងមិនបង្កគ្រោះថ្នាក់ឡើយ។[5]

## ការមានកូន

មិនមានភស្តុតាងណាមួយដែលបង្ហាញថាថ្នាំបង្ការជំងឺ COVID-19 បណ្តាលឱ្យមានការរលូតកូន ឬកាត់បន្ថយឱកាសនៃការមានកូនចំពោះស្ត្រី ឬបុរសនោះទេ។[2,4]

## ព័ត៌មានអំពីថ្នាំបង្ការ



អត្ថប្រយោជន៍នៃថ្នាំបង្ការទាំង 3 ប្រភេទនេះគឺមានច្រើនជាងហានិភ័យ។

ថ្នាំបង្ការប្រភេទ PFIZER (COMIRNATY)
ចំនួន 2 ដូស - ដោយគម្លាត 21ថ្ងៃ

ថ្នាំបង្ការប្រភេទ MODERNA
ចំនួន 2 ដូស - ដោយគម្លាត 28ថ្ងៃ

ថ្នាំបង្ការប្រភេទ J & J
ចំនួន 1 ដូស

ទាំងអស់៖ ការចាក់ថ្នាំជំរុញនាពេលអនាគត

មានថ្នាំបង្ការជំងឺ COVID-19 ចំនួនបីប្រភេទផ្សេងៗគ្នាដែលអាចរកបាននៅសហរដ្ឋអាមេរិក។ ថ្នាំបង្ការទាំងនេះត្រូវបានបង្ហាញថាមានសុវត្ថិភាព និងមានប្រសិទ្ធភាព។[6]

អ្នកមិនអាចកើតជំងឺ COVID-19 ដោយសារការចាក់ថ្នាំបង្ការនេះទេ។ គ្មានថ្នាំបង្ការណាមួយមានផ្ទុកមេរោគដែលបង្កឱ្យមានជំងឺ COVID-19 នោះទេ។[6]

មានហានិភ័យទាក់ទងនឹងស្ថានភាពធ្ងន់ធ្ងរ ប៉ុន្តែកម្រកើតមានមួយ ដែលពាក់ព័ន្ធនឹងការកកឈាមនិងប្លាកែតចុះទាប ចំពោះអ្នកដែលបានចាក់ថ្នាំបង្ការប្រភេទ J&J។ បញ្ហានេះបានកើតឡើងលើស្ត្រីប្រហែលចំនួន 7 ករណីក្នុងចំណោមស្ត្រីដែលបានចាក់ថ្នាំបង្ការចំនួន 1 លាននាក់ដែលមានអាយុចន្លោះពី 18-49 ឆ្នាំ។ ហានិភ័យនៃការកកឈាមគឺមានកម្រិតខ្ពស់ខ្លាំងជាមួយនឹងការឆ្លងជំងឺ COVID-19 ជាងការចាក់ថ្នាំបង្ការ។[7,8]

VaccinateLACounty.com
Revised 9/1/21(Cambodian)

County of Los Angeles Public Health

# ព័ត៌មានបន្ថែមស្តីពីថ្នាំបង្ការជំងឺ COVID-19 ការមានផ្ទៃពោះ និងការផលិតទឹកដោះ៖

- សំណួរបានសួរជាញឹកញាប់អំពីថ្នាំបង្ការ COVID-19 របស់សុខភាពសាធារណៈនៃខោនធី Los Angeles ៖ការមានផ្ទៃពោះ ការបំបៅដោះកូន និងការអាចមានកូនមាននៅគេហទំព័រ៖ VaccinateLACounty.com
- គេហទំព័រថ្នាំបង្ការជំងឺ COVID-19 អំឡុងពេលមានផ្ទៃពោះឬបំបៅដោះកូន របស់ CDC មាននៅ៖ https://www.cdc.gov/coronavirus/2019-ncov/vaccines/recommendations/pregnancy.html
- គេហទំព័រថ្នាំបង្ការជំងឺ COVID-19 សម្រាប់អ្នកដែលចង់មានកូនរបស់ CDC មាននៅ៖ https://www.cdc.gov/coronavirus/2019-ncov/vaccines/planning-for-pregnancy.html
- ព័ត៌មានថ្នាំបង្ការជំងឺ COVID-19 ប្រសិនបើអ្នកមានផ្ទៃពោះ ឬបំបៅដោះកូនរបស់សង្គមវេជ្ជសាស្ត្រសម្រាប់មាតានិងទារក

## វិធីទទួលការចាក់ថ្នាំបង្ការ៖

សូមចូលទៅគេហទំព័រ www.vaccinate LACounty.com ហើយចុចលើ “វិធីទទួលការចាក់ថ្នាំបង្ការ” (“How to Get Vaccinated”) ដើម្បីរកទីតាំងនៅជិតអ្នក។

តាមទីតាំងជាច្រើន មិនចាំបាច់តម្រូវធ្វើការណាត់ជួបទេ។ ថ្នាំបង្ការគឺមិនគិតថ្លៃហើយអ្នកមិនត្រូវការធានារ៉ាប់រងទេ។ អ្នកនឹងមិនត្រូវបានសួរនាំអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកឡើយ។

អ្នកក៏អាចទូរស័ព្ទទៅមជ្ឈមណ្ឌលព័ត៌មានថ្នាំបង្ការតាមរយៈទូរស័ព្ទលេខ 833-540- 0473។ មជ្ឈមណ្ឌលទទួលទូរស័ព្ទបើកបម្រើការជារៀងរាល់ថ្ងៃចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8:30 យប់ ហើយអាចជួយអ្នកបានក្នុងការ៖

- ស្វែងរកទីតាំងនៅម្តុំជិតអ្នក
- រៀបចំការដឹកជញ្ជូនទាំងទៅនិងមក ពីកន្លែងចាក់ថ្នាំបង្ការ
- ស្នើសុំការចាក់ថ្នាំបង្ការនៅផ្ទះ ប្រសិនបើអ្នកមិនអាចធ្វើដំណើរចេញពីផ្ទះបាន


1ACOG and SMFM Recommend COVID-19 Vaccination for Pregnant Individuals. https://www.acog.org/news/news-releases/2021/07/acog-smfm-recommend-covid-19-vaccination-for-pregnant-individuals

2 CDC. CDC Data: COVID-19 Vaccination Safe for Pregnant People. https://www.cdc.gov/media/releases/2021/s0811-vaccine-safe-pregnant.html

3CDC. Pregnant and Recently Pregnant People at Increased Risk from Severe Covid-19. https://www.cdc.gov/coronavirus/2019-ncov/need-extra-precautions/pregnant-people.html

4 CDC. COVID-19 Vaccines While Pregnant or Breastfeeding. https://www.cdc.gov/coronavirus/2019-ncov/vaccines/recommendations/pregnancy.html

5 NIH. COVID-19 Vaccines and the Menstrual Cycle. https://covid19.nih.gov/news-and-stories/covid-19-vaccines-and-menstrual-cycle

6 CDC. Ensuring COVID-19 Vaccine Safety in the US. https://www.cdc.gov/coronavirus/2019-ncov/vaccines/safety.html

7CDC. CDC Recommends Use of Johnson and Johnson’s Janssen COVID-19 Vaccine Resume. https://www.cdc.gov/coronavirus/2019-ncov/vaccines/safety/JJUpdate.html

8CDC. What do I need to know about Johnson & Johnson’s Janssen COVID-19 Vaccine (J&J/Janssen) now? https://www.cdc.gov/coronavirus/2019-ncov/downloads/vaccines/324167-a-consumer-facing-three-vaccines-8.5x11-final-print.pdf